KPI 0497

**សម្ភាសន៍ជាមួយឈ្មោះ ជីវ ជឿន ភេទប្រុស អាយុ៦០ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ នីរសា និងកាន់ខាងគេអូ**

**សព្វថ្ងៃរស់នៅភូមិដូនឪ ឃុំស្នាយអញ្ជិត ស្រុកជុំគិរី ខេត្តកំពត**

**ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី**

**០១:០៨:៣០**

**២៣ទំព័រ**

ដានី ៖ ពូជីបូងអីចឹងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះពេញឈ្មោះអីដែរ?

ជឿន ៖ ឈ្មោះខ្ញុំតាំងពីកំណើតកើតជាមកខ្ញុំដាក់តែជីវ ជឿនៗហ្នឹងរហូតអត់ដែលដូរឈ្មោះទេទៅកន្លែងណាក៏ដូចកន្លែងណាដែរ ។

ដានី ៖ ជីវ ជឿន?

ជឿន ៖ បាទ!

ដារ៉ា ៖ អាយុ ប៉ុន្មានឆ្នាំហើយពូ?

ជឿន ៖ ចូល ៦០ហើយ ។

ដារ៉ា ៖ ៦០ គត់?

ជឿន ៖ ៦០ គត់ហ្នឹង

ដារ៉ា ៖ មានស្រុកកំណើតកើតជានៅណា?

ជឿន ៖ នៅហ្នឹងហ្នឹង ភូមិដូនឪ ឃុំត្រពាំងរាំង ស្រុកឈូក ខេត្តកំពត តែឥឡូវគេដូរឈ្មោះហើយស្រុកជុំគិរីហើយ ។

ដានី ៖ ឃុំត្រពាំងរាំង?

ជឿន ៖ ឥឡូវឃុំស្នាយជិត ។

ដារ៉ា ៖ កាលមុនគេដាក់ស្រុកអី ស្រុកឈូក?

ជឿន ៖ ស្រុកឈូក ។

ដារ៉ា ៖ ពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ជឿន ៖ ខ្ញុំមានបងប្អូនដល់៨នាក់ឯណោះតែឥឡូវអស់ហើយសល់តែ៤ទេ ។

ដារ៉ា ៖ ប្រុសស្រីប៉ុន្មាននាក់?

ជឿន ៖ ប្រុសមានតែ២នាក់ ប៉ុន្តែស្លាប់បាត់មួយនៅតែខ្ញុំមួយហ្នឹង ហើយស្រីនៅ៣នាក់ ។

ដាវ៉ា ៖ ចឹងមានន័យថាប្រុស២ ស្រី៦?

ជឿន ៖ បាទ!

ដាវ៉ា ៖ ប្រុសស្លាប់ម្នាក់ ស្រីស្លាប់៤ ចឹងហេ?

ជឿន ៖ ស្រីស្លាប់៣!

ដាវ៉ា ៖ ស្រីស្លាប់៣ និងប្រុស១ ស្លាប់ដោយសារអីពូ?

ជឿន ៖ ស្លាប់ ប្រុសនោះស្លាប់ទៅបាត់រហូតគេធ្វើទ័ពដើងទឹកស្លាប់បាត់រហូត បើស្រីស្លាប់ដោយសារជម្ងឺ ។

ដាវ៉ា ៖ ធ្វើទ័ពដើងទឹក?

ជឿន ៖ ដើងទឹកទៅបាត់មួយហើយប្អូនខ្ញុំ ។

ដានី ៖ គាត់ឈ្មោះអី?

ជឿន ៖ ឈ្មោះជីវ ចាម មើលគ្រូគេមិនទាន់ស្លាប់មិនដឹងព្រោះទៅដើងទឹកយើងអត់អាចដឹងណាស ។

ដាវ៉ា ៖ ជីវអី ជីវ ចាប?

ជឿន ៖ ជីវ ចា ដាក់ម ។

ដាវ៉ា ៖ ទៅហ្នឹងមួយរយៈមួយពូដែរហ្នឹងហ្អី?

ជឿន ៖ ទៅក្រោយ វាក្មេងក្រោយក្រោយខ្ញុំ ។

ដាវ៉ា ៖ គ្រួសាពូឈ្មោះអីដែរ?

ជឿន ៖ គ្រួសារខ្ញុំកាលពីមុននោះឈ្មោះលឹម អិត ដល់ខ្ញុំលែងលះគ្នាទៅយកគ្រួសារខ្ញុំក្រោយនេះបានឃួន ពៅ ។

ដាវ៉ា ៖ លឹម អិត ហ្នឹងមានកូនចៅដែរ?

ជឿន ៖ មាន៤នាក់ ។

ដាវ៉ា ៖ ចុះជាមួយមីងពៅមានកូនប៉ុន្មាននាក់?

ជឿន ៖ ៧ ច្រើនណាស់ លែងគ្នាតាំងពីខ្ញុំចុះពីរត់មករហូត ។

ដាវ៉ា ៖ ៧ មុន៤ ១១ ចុះកូនបស់ពូ៤នាក់មុននៅរស់ដែរ?

ជឿន ៖ ស្លាប់១ហើយនៅ៣ ។

ដាវ៉ា ៖ នៅម៉ុំណា?

ជឿន ៖ នៅក្បែរៗគ្នាហ្នឹង ។

ដារ៉ា ៖ នៅក្នុងភូមិនេះដែរ?

ជឿន ៖ បាទ នៅក្នុងភូមិហ្នឹង ។

ដារ៉ា ៖ ហើយគ្រួសារមុនស្លាប់ដែរម្ដេច?

ជឿន ៖ នៅ ។

ដារ៉ា ៖ ចឹងមួយមីងក្រោយនេះបាន៧នាក់?

ជឿន ៖ បាន៧ ។

ដារ៉ា ៖ ឪពុកម្ដាយពូឈ្មោះអីដែរ?

ជឿន ៖ ឪពុកខ្ញុំស្លាប់ហើយ ជីវ ញ៉ែម ជីវ

ដារ៉ា ៖ ហើយម្ដាយ?

ជឿន ៖ ម្ដាយរស់ លួន ម្ដាយនៅទេ ។

ដារ៉ា ៖ ម្ដាយនៅចឹងណោះ អូអាយុច្រើនហើយចឹង?

ជឿន ៖ ៨០ ជាងហើយ ។

ដារ៉ា ៖ ម្ដាយ រស់ នៅ ចឹងហ្អី?

ជឿន ៖ បាទ! នៅ ។

ដារ៉ា ៖ ឈ្មោះយាយនៅ?

ជឿន ៖ យាយលួន!

ដារ៉ា ៖ រស់ លួន?

ជឿន ៖ បាទ! មិនមែនរស់នៅទេ ។

ដារ៉ា ៖ កាលពីពូនៅតូចៗនៅជាកុមារមានបានចូលរៀនចូលសូត្រអីដែរ?

ជឿន ៖ បានរៀននៅវត្តអង្គបឹងចកហ្នឹង ។

ដារ៉ា ៖ រៀនបានត្រឹមថ្នាក់ទីប៉ុន្មាន?

ជឿន ៖ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ មិនបានប្រលងនឹងគេទេមួយឆ្នាំហ្នឹងអត់ជាប់ឆ្នាំទី១ ។

ដារ៉ា ៖ បានថ្នាក់ទី៧ មានន័យថាថ្នាក់ក្មេសយើងហ្នឹងថ្នាក់បឋមសិក្សា?

ជឿន ៖ ឥឡូវយើងនេះមិនដឹងទីប៉ុន្មានទេ ខ្ញុំពីមុនមកទី៧ ។

ដារ៉ា ៖ ទី៧ បើគេរាប់ពី១២ឡើងមកទី១ចឹងណា ពី១២មកទី៧រៀនបាន៦ឆ្នាំ បើគិតទៅវានៅក្នុង
បឋមសិក្សានៅឡើយទេ តែចេះសរសេរចេះអានអី?

ជឿន ៖ បានអានខ្លះ សរសេរកើតខ្លះចឹងដែរ ។

ដារ៉ា ៖ ហេតុអីបានជារៀនត្រឹមថ្នាក់ទី៧ចឹង?

ជឿន ៖ វាអីចេះ ដល់ពេលហ្នឹងវាត្រូវប្រទេសជាតិវាវាចលាចលច្របូកច្របល់អីជជីកវរ ដល់ពេលគេរដ្ឋប្រហាររដ្ឋអី ។

ដារ៉ា ៖ ចឹងមានន័យថាពូរៀនបានត្រឹមថ្នាក់ទី៧នៅក្នុងពេលមានរដ្ឋប្រហារនៅក្នុងឆ្នាំ៧០?

ជឿន ៖ បាទ! គេរដ្ឋប្រហាររញ៉េរញ៉ៃមិនដឹងជាស្អីៗតិចលឺថាចេះតិចលឺថា ចុះមនុស្សនៅអត់សុខដែរហ្នឹង ។

ដារ៉ា ៖ ចុះនៅពេលហ្នឹងនៅក្នុងភូមិឃុំពូរស់នៅមានសភាពម៉េចទៅ?

ជឿន ៖ ក្នុងភូមិនេះគ្មានទេតែដូចនៅខាងស្រែចែង ដូចទៅព្រៃវែងព្រៃអីនោះ ពួថាខ្មែរក្រហមអីចេះអីចុះរួមផ្សំសម្តេច យើងឃោសនារួបរួមគ្នាចូលព្រៃម្រឹង គឺម្រឹងគា ដើម្បីតស៊ូរំដោះជាតិកុំឲ្យពួកលន់ នល់ វាឈ្មានពាននោះ លន់ នល់ គេមិនធ្វើរដ្ឋប្រហារ ពេលហ្នឹងញ៉េរញ៉ៃ ច្របូកច្របល់ពេញទឹកពេញដី ។

ដារ៉ា ៖ ពេលហ្នឹងក្នុងចិត្តពូមានការគិតគូរយ៉ាងម៉េចទៅនៅពេលប្រទេសជាតិញ៉េញ៉ៃ?

ជឿន ៖ គិតគូរតែចេះយើងជាប្រជាពលរដ្ឋអត់មានគិតគូរអីទេគិតគូរឲ្យទៅកន្លែងណាស្រួលហើយណាម្យ៉ាងកាលជំនាន់នោះឪពុកម្តាយ ជីដូនជីតា បងប្អូនយើងជងទាំងឡាយជំនឿទៅខាងសម្តេចជឿស្តេច ដែលលោកមានមហិទ្ធិឫទ្ធិខ្លាំងពូកែ ម៉្លោះហើយលោកស្រែកថា ម៉េចចេះតែជឿតាម គាត់ចឹងទៅ ។

ដារ៉ា ៖ ចឹងពេលដែលមានការអំពាវនាវបែបហ្នឹងចឹងទៅពូធ្វើម៉េចទៀតទៅ?

ជឿនៈ មិនទាន់បានចូលទៅណាទេ នៅក្នុងភូមិប្រធានអីគេដូចថាបងប្អូនប្រធានភូមិគេចាត់តាំងឲ្យ ខ្ញុំធ្វើគ្រូបង្រៀនចឹងទៅក៏ស្ម័គ្រចិត្តធ្វើគ្រូបង្រៀនគេទៅគ្រូបង្រៀនក្មេង ។

ដារ៉ា ៖ គ្រូបង្រៀនក្មេង?

ជឿន ៖ បាទ! គ្រូបអ្រៀនក្មេងនៅក្នុងភូមិ ។

ដារ៉ា ៖ នៅភូមិដូនឪនេះ?

ជឿន ៖ បាទ! បង្រៀនតាមព្រៃតាមកំពោចកប៉ាល់ហោះទម្លាក់អត់នឹកឃើញអីទេ នឹកឃើញតែរឿងបង្រៀនជងធ្វើស្រែធ្វើភ្លឺដោយភ័យខ្លាចកប៉ាល់ហោះ យើងគ្មាននឹកឃើញស្អីទេ ។

ដារ៉ា ៖ មានទម្លាក់គ្រាប់បែកដែរ?

ជឿន ៖ យីទម្លាក់ខ្លាំងដែរតើ ផ្សារទម្លាក់ខ្ទេចខ្ទីទាំងអស់គាប់មិនតិចដែលហ្នឹងណា ។

ដារ៉ា ៖ ផ្សារអីគេ?

ជឿន ៖ ផ្សារវត្តចកហ្នឹងកប៉ាល់ហោះទម្លាក់ កាលពីមុនវត្តចកឥឡូវហៅជុំគិរី កប៉ាល់ហោះទម្លាក់អាធុនសាំងឆេះពេញទឹកពេញដី ។

ដារ៉ា ៖ ពេលមានការទម្លាក់គ្រាប់បែកចឹង ទៅដូចថាអារម្មណ៍ប្រជាជននៅតាមភូមិគាត់មាន...?

ជឿន ៖ មានការភ័យខ្លាចដឹកគ្រួសារសេតាមដំបូក ហើយការបង្រៀនក្មេងដូចខ្ញុំនិយាយចឹងបង្រៀនតាមកំពោចព្រៃ តាមអូរចឹងទៅ មានដំបូងណាមានព្រៃឈើច្រើនទៅធ្វើសាលារៀនខាងក្រោមហ្នឹងចឹងទៅ ។

ដារ៉ាៈ តើអ្នកស្រុកអ្នកភូមិមានបានគិតទេតើត្រូវធ្វើយ៉ាងម៉េចទាក់ទងការទម្លាក់គ្រាប់បែកហ្នឹងអ្នកស្រុកអ្នកភូមិមានជាកំហឹងឬមានជាស្អីយ៉ាងម៉េចតទៅទៀតត្រូវធ្វើយ៉ាងម៉េច?

ជឿន ៖ កំហឹងឈឺចាប់ស្អីដូចជា អត់មានទឹករឿងឃើញកំហឹង មានតែទឹកឃើញរឿងនាំគ្នាធ្វើស្រែធ្វើភ្លឺបានស្រូវបានអង្ករ ទឹកឃើញតែពួន ពួនក្នុងព្រៃឲ្យបានសុខគ្រាន់តែលឺកប៉ាល់ហោះមកឯណាតែផ្សែងភ្លើងដាំបាយមិនឲ្យឃើញផ្សែងភ្លើងផង ។

ដារ៉ា ៖ កាលហ្នឹងមានការនិយាយឬឃោសនាយ៉ាងមេច បានជាប្រជាជនមានការភ័យខ្លាច?

ជឿន ៖ អត់មានអ្នកណាឃោសនាអីទេ វាទម្លាក់ដាក់ស្តែងពេក ទម្លាក់នៅផ្សារចឹងអាបេ៥២ ទម្លាក់ភ្នំកើតអណ្តូងប៉ុនណាណឺម៉ាគ្រាប់ៗក្រឡុកជំរៅ៣, ៤, ៥ម៉ែត្រទៅក្រោម ហើយមាត់អណ្តូងប្រហែល៨,១០ម៉ែត្រ អាណាមិនខ្លាចវាទម្លាក់ម្តងៗមាន២០, ៣០គ្រាប់ ។

ដារ៉ា ៖ ចឹងកាលហ្នឹងនៅក្នុងរវាងឆ្នាំណា?

ជឿន ៖ ដូចខ្ញុំបានជំរាបចឹងអត់បានកត់សំគាល់ឆ្នាំទេ ។

ដារ៉ា ៖ ប៉ុន្តែគ្រាន់តែចង់និយាយថា បន្ទាប់ពីការទម្លាក់សម្តេចព្រះនរោត្តម សីហនុ ហើយឬនៅ? មុន ឬក្រោយ?

ជឿន ៖ ទម្លាប់ ហើយបានកើតមានបញ្ហាទម្លាក់គ្រាប់បែកហ្នឹង ។

ដារ៉ា ៖ ចុះបន្ទាប់ពីពូបង្រៀនក្មេង ហើយមានទម្លាក់គ្រាប់អីចឹង តើការវិវត្តទៅមុខទៀតយ៉ាងម៉េចទៅ?

ជឿន ៖ រឿងហ្នឹងពិបាកចាំណាស់លោកក្មួយ ដូចខ្ញុំថា រកកំណត់ពេលមិនចាំចឹង ណាវាអត់បានទឹកកត់កំណត់ជាហេតុសំរាប់ធ្វើការជាប្រវត្តិសាស្ត្រអីអត់ណាស ដូច្នេះដឹងថាកាលៈទេសៈណាមកដល់គេចតាមដំណើរចឹងទៅ ។

ដារ៉ា ៖ តែឥឡូវពូបានរៀបរាប់មកដល់ត្រឹមកន្លែងដែលថា ពូធ្វើជាបង្រៀនក្មេងតាមភូមិ ហើយមានការទម្លាក់គ្រាប់បែកមានការរត់គេច ចុះបន្ទាប់ពីហ្នឹងទៅវាយ៉ាងម៉េច?

ជឿន ៖ បន្ទាប់ពីហ្នឹងទៅខ្ញុំបាន ជំរាបលោកក្មួយឯងពីខាងដើមចឹងណា មានទំនាស់ជាមួយប្រធានភូមិ ដែលគេស្លាប់បាត់ហ្នឹងណា ក្មេងដែលគេយកក្មេងបង្ហាត់សិល្បះចឹងទៅខ្ញុំបង្រៀនក្មេង ក្មេងវាចេះតែរឹងក្បាលពិបាកបង្រៀនក្មេងទៅអត្តុយរៀនវាចេះរឹងក ដល់ពេលចឹងទំនាស់គ្នា គេមានការរាយការណ៍ទៅលើអីចឹង ទៅខាងលើគេត្រូវជាមួយខ្ញុំ គេមកប្រាប់ពីសេចក្ដីរាយការណ៍ពីភូមិចេះមួយចេះពីរ ខ្ញុំក៏ស្ម័គ្រចិត្តសុំទៅធ្វើទាហាន ។

ដារ៉ា ៖ ទៅធ្វើទាហានហ្នឹង មុនដំបូងចូលនៅក្នុងកងណាៗ?

ជឿន ៖ អត់មានកងទេអាហ្នឹងគេហៅថាទៅធ្វើឈ្លបឃុំ ។

ដារ៉ា ៖ ឃុំណា?

ជឿន ៖ ឃុំស្រែចែង កាលហ្នឹងនៅឃុំស្រែចែង ។

ដារ៉ា ៖ គ្រាន់តែនៅក្នុងឈ្លបឃុំ តើពូនៅបានប៉ុន្មានឆ្នាំ?

ជឿន ៖ អត់ដឹងឆ្នាំទៀតហើយអាហ្នឹង ។

ដារ៉ា ៖ អត់ទេចង់និយាយថាធ្វើបានរយៈពេលប៉ុន្មានដែលយូរទេ?

ជឿន ៖ ចឹងបានថា វាចេះតែធ្វើៗដល់នេះគេត្រូវការដើររកខ្មាំងបង្កប់ក្នុងព្រៃអីណា គេហៅដើររកខាងលិចបាក់ទឹមអីចឹងទៅស្រាប់តែគេឲ្យទៅៗនឹងគេចឹងទៅ ។

ដារ៉ា ៖ ចឹងមានន័យថានៅពេលដែលពូធ្វើឈ្លបឃុំហ្នឹងភារៈកិច្ចរបស់ឈ្លបឃុំគឺដើររក..?

ជឿន ៖ ដើររកអាពួកព្រៃគេហៅពួកអាយក់សាន់នៅព្រៃ ។

ដារ៉ា ៖ ពួកហ្នឹងយ៉ាងមេចវាប្រឆាំងហ្នឹង?

ជឿន ៖ ពួកហ្នឹងវាប្រឆាំងជាមួយ គេចោទថាពួកសេរ៊ីអារបស់ពួកលន់ នល់ ។

ដារ៉ា ៖ ចឹងមានការធ្វើល្បាតដើររុករកតាមព្រៃ?

ជឿន ៖ បាទ ដើររុករកតាមព្រៃឃើញកន្លែងវាដាំបាយអីហូបចឹងដែរហ្នឹង ។

ដារ៉ា ៖ ចុះមានដែលចាប់បានទេ?

ជឿន ៖ អត់ដែលចាប់បានទេ ។

ដារ៉ា ៖ ហើយឈ្លបឃុំមានកាន់កាំភ្លើងអីដែល?

ជឿន ៖ មាន អវុធគេឲ្យកាន់ហ្មង ។

ដារ៉ា ៖ ពូកាន់កាំភ្លើងម៉ាកអី?

ជឿន ៖ កាំភ្លើងកាលហ្នឹងគេឲ្យកាន់ការ៉ាប៊ីនអ៊ីមអង ។

ដារ៉ា ៖ ១០០ ប៉ុន្មាន?

ជឿន ៖ មិនមែន១០០ទេ ការ៉េនអ៊ីមអន ការ៉េភ្លើងហ្នឹងណា ការ៉េភ្លើងដៃហ្នឹងណាប៉ុន្តែគេហៅការ៉េនអ៊ីមអន មួយបង់វាមាន៥ ៦គ្រាប់ហ្នឹងណា ។

ដារ៉ា ៖ អាវែងៗហ្នឹង?

ជឿន ៖ បាទ អាវែងៗ ។

ដារ៉ា ៖ ឈ្លបឃុំហ្នឹងទទួលភារៈទទួលកិច្ចការងារពីណាពីឃុំប្តុក៏ពី...?

ជឿន ៖ ដូចអត់ទាន់មានភារៈកិច្ចការងារអីទេលោកក្មួយកាលហ្នឹងដូចអត់ទេ ដឹងចេះតែធ្វើទៅអត់មាន ទទួលភារៈកិច្ចការងារអីណាអីក៏អត់ដឹងដែរ គេដាក់រួមគ្នាឈ្លបឃុំចឹងទៅមិនដឹងពីណាដឹកនាំណា អត់ដឹងគ្រាន់តែទៅតាមគេចឹងទៅមេខ្លួនឯងមិនដឹងណាគេផង ចេះតែទៅគេឯងចឹងទៅ គេទៅ រកឃើញកន្លែងដាំបាយថាកន្លែងដាំបាយគេចឹងទៅមើលឃើញភ្លើងស្នាមហុយៗមែន ទៅអី ចឹងទៅ ។

ដារ៉ា ៖ ចុះពេលរស់នៅអីដូចថា ជាឈ្លបភូមិនៅម៉ុំក្នុងភូមិក្នុងអីមានកន្លែងគេដែរ?

ជឿន ៖ ក្នុងភូមិអត់មានទេអត់ឃើញមានឈ្លបទេ មានតែឈ្លបឃុំអីពេលយើងត្រូវការអីពីឃុំ គេយក អន្តរយកដព្រៃឡូហូបចឹង ទៅមួបចឹងទៅពីឃុំគេយកទៅ ក្រោមការគ្រប់គ្រងរបស់ឃុំកាល ហ្នឹងតាមមើល ។ វាអត់មានអ្នកគ្រប់គ្រងពិតប្រាកដផង ។

ដារ៉ា ៖ ហើយចេះតែទៅទៅ?

ជឿន ៖ ចេះតែទៅតាមដំណើរ ចឹងទៅបើតាមគិតទៅដូចជា ជំនាន់ហ្នឹងដល់ពេលយើងត្រូវតែទៅ ទោះបី មានប្រាក់ខែក៏ទៅមិនមានប្រាក់ខែក៏ទៅ ទោះបីងាប់ក៏ទៅរស់ក៏ទៅចេះតែទៅណា ។

ដារ៉ា ៖ ទៅដោយអត់មានគោលដៅច្បាស់លាស់ទេចុះ?

ជឿន ៖ អត់មានច្បាស់លាស់ទេ អត់ទាន់ដឹងមានច្បាស់លាស់ទេ កាលហ្នឹងសង្គ្រាមអត់ទាន់មានខ្លាំងក្លា ដែលអត់ទាន់មានពិតប្រាកដ ក្នុងសង្គ្រាមឈ្លប ព្រួសូរគ្រាន់ណាចេះតែទៅដូចអត់មាននឹកគិត ។

ដារ៉ា ៖ នៅក្នុងក្រុមពូមានប៉ុន្មាននាក់ពេលទៅម្តងៗ?

ជឿន ៖ ទេ ច្រើនដែរប្រហែល ៣០នាក់

ដារ៉ា ៖ អត់មានស្គាល់ពីណាម្នាក់សោះ?

ជឿន ៖ ស្គាល់ប៉ុន្តែនៅរហូរដូចថាអ្នកទាំងអស់ហ្នឹងវាទៅឆ្ងាយៗដូចអត់ដែលឃើញផងឥឡូវដូចជា ស្លាប់បាត់អស់ហើយមិនដឹង ។

ដារ៉ា ៖ ម៉ាជំនាន់ពូដែលចូលជាមួយគ្នា មានមិត្តភក្ត័ពូណាខ្លះ ដែលពូអាចចាំឈ្មោះ ទោះបីស្លាប់ក៏ ដោយ?

ជឿន ៖ ចាំ ចាំច្រើនដែលហ្នឹងតែវាទៅបាត់ៗអស់អត់មានឃើញមួយផង ។

ដារ៉ា ៖ រៀបរាប់មើលថា តើចាំឈ្មោះប៉ុន្មាននាក់?

ជឿន ៖ ហេស! ពិបាកចាំណាស់យូរពេក ឆ្ងាយពេក បើឃើញមនុស្សបើវាទៅបាត់ចឹងណាហើយ ក្រោយមកយើងឃើញមនុស្សទៅចេះតែនឹកឃើញឈ្មោះទៅ ចុះបើវាទៅឆ្ងាយៗបាត់រហូត ដូចដីកកប់មិនបាន នឹកភ្នកឿងចាំឈ្មោះចាំអីទេ វាគ្មានការចងចាំ ។

ដារ៉ា ៖ ពេលដែលពូធ្វើឈ្លបឃុំហើយបន្តទៅពីឈ្លបឃុំហ្នឹងទៅចេញទៅជាស្អីទៀតទៅ?

ជឿន ៖ ចេញទៅគេហៅថាកងទ័ពតំបន់ ។

ដារ៉ា ៖ អត់មានឆ្លងកាត់ស្រុកអីទេ?

ជឿន ៖ អត់ទេ! ទៅកងទ័ពតំបន់ម៉ង ហៅថានេះគេបញ្ជូនទៅតំបន់ ។

ដារ៉ា ៖ តំបន់អីគេពូ?

ជឿន ៖ តំបន់កំពត ។

ដារ៉ា ៖ កាលហ្នឹងគេហៅមានលេខអីដែល?

ជឿន ៖ អត់ទាន់មានលេខទេដល់ចូលបាន១ខែ ២ខែ បានគេយកទៅដាក់ហៅថាកង៥១ អាហ្នឹងមាន លេខហើយ ។

ដារ៉ា ៖ កង៥១ជាកងយ៉ាងមេច?

ជឿន ៖ កងទ័ពគេ ឈ្មោះ៥១ វរៈ៥១ ។

ដារ៉ា ៖ វរៈ៥១ វរៈហ្នឹងវរៈតូចទេហ្អី?

ជឿន ៖ វរៈសេនាតូច៥១ វាយូរពេកចឹងពិបាកចាំ ។

ដារ៉ា ៖ អ្នកណាគេជាប្រធានវរៈ?

ជឿន ៖ ប្រធានវរៈផ្លាស់ប្តូរកាលមុន តាឆៃ ។

ដារ៉ា ៖ ពេលពូទៅភ្លាមហ្នឹងប្រធានវរៈ តាឆៃ?

ជឿន ៖ ឈ្មោះ ឆៃ បានក្រោយមក តាចិន ។ តាចិនៗ ហ្នឹងកប៉ាល់ហោះទំលាក់ឆេះវៀចមុខវៀច មាត់អស់ហើយ ឆេះអស់លីងឆេះដល់មាត់នោះទូចដូចត្រីឆ្អញហូបបាយនឹងកូនស្វាបព្រាតូច ។

ដារ៉ា ៖ វរសេនាតូចរបស់ពូ វរសេនាតូច៥១ ច្រើនធ្វើការងារនៅម្តុំណា?

ជឿន ៖ នៅជុំវិញកំពត

ដារ៉ា ៖ ជុំវិញខេត្តកំពត?

ជឿន ៖ បាទ ច្រើនដើរឆ្នក់ ដើរឈ្លប ដើរវៃ ត្រូវលើកទិសវៃនៅជុំវិញខេត្តកំពតហ្នឹងម៉ង ទីណាមាន ទាហានទៅត្រង់ហ្នឹង ។

ដារ៉ា ៖ តែជុំវិញខេត្តកំពតទេ?

ជឿន ៖ បាទ!

ដារ៉ា ៖ សកម្មភាពហ្នឹងមានរហូតដល់ពេលណា?

ជឿន ៖ យូរ! យូរមែនទែនរហូតដល់ក្រោយមកពេលគេបើកយុទ្ធនាការវៃទីក្រុងភ្នំពេញ កងខ្ញុំគេឲ្យទៅ វៃនៅម្តុំទឹកសាបតាមផ្លូវជាតិលេខ៤នេះ ឲ្យទ័ពចេញពីកំពង់សោមមកទៅបុកគេនៅត្រែង ត្រយឹងផ្លូវផ្លូវជាតិលេខ៤ កុំឲ្យវៃគេពីខ្នងគេឲ្យទៅវៃនៅទប់ទឹកសាប កងកេងហ្នឹង ។

ដារ៉ា ៖ កង៥១របស់ពូហ្នឹងហេ កង៥១ហ្នឹងត្រូវបានឲ្យទៅណា?

ជឿន ៖ ទៅវៃនៅទឹកសាប ។

ដារ៉ា ៖ ហេតុអីបានទៅកន្លែងហ្នឹងវិញ?

ជឿន ៖ គេលើកទិសដាក់យុទ្ធនាការវៃភ្នំពេញខ្លាំង វៃភ្នំពេញដើម្បីកុំឲ្យអាកម្លាំងពីកំពង់សោមនេះទៅ ជួយភ្នំពេញយកកងខ្ញុំទៅវៃទប់នៅផ្លូវជាតិលេខ៤ ។

ដារ៉ា ៖ កន្លែងហ្នឹងម្តុំណាពូ?

ជឿន ៖ ម្តុំទឹកសាបខាងកើតកំពង់សោម ខាងកើតវ៉ាកងកេងខាងកើតវាលយន្តហោះកងកេងនេះ អា រឿងតស៊ូនោះវាវែងណាស់ ។

ដារ៉ា ៖ ចឹងយុទ្ធនាការវាយយកភ្នំពេញហ្នឹង កងពូគេឲ្យទៅវាយទប់នៅកន្លែងកងកេងហ្នឹង មានសកម្ម ភាពជាការវាយទប់មែនឬក៏យ៉ាងម៉េច?

ជឿន ៖ វាយទប់មែន ហើយកប៉ាល់ហោះទំលាក់ម៉ាថ្ងៃយ៉ាងតិចក៏៥០ដងដែរ ។

ដារ៉ា ៖ ទំលាក់កន្លែងហ្នឹងនឹង?

ជឿន ៖ បាទ ទំលាក់តាមខ្សែត្រៀមហ្នឹងទាំងដើងទឹកក៏វាផ្សោងដាក់ពួកខ្ញុំកប៉ាល់ហោះកងកេងក៏វាទំលាក់ ឡើង២ចុះ២ៗក្នុងម៉ាថ្ងៃអត់មានទំនេរទេ វ៉ាកងកេងនៅជិតបង្កើយហ្នឹង ។

ដារ៉ា ៖ នៅជិតហ្នឹងដែលចុះខ្សែត្រៀមពូនៅក្បែរហ្នឹងក៏មិនវាយ?

ជឿន ៖ ទេ! មិនក្បែរពេកទេប្រហែលជីខ្ទង់២០ ៣០គីឡូដែល ប៉ុន្តែកប៉ាល់ហោះមិនដឹងគ្រាន់តែឡើង មកទំលាក់ហើយអា២នេះឡើងអា២នោះចុះចាប់គ្រាប់ ហើយឡើងមកទៀតអា២នេះចុះអា២ នោះឡើងវាល់ល្ងាច ឲ្យតែភ្លឺឡើងចាប់ផ្តើមវាទំលាក់រហូត ។

ដារ៉ា ៖ ចុះកងទ័ពពូឈរកន្លែងហ្នឹងចឹង អត់មានផែនការណ៍វៃឆ្មក់ចូល ដើម្បីកំទេចកន្លែងហ្នឹងទេហោះ?

ជឿន ៖ ផែនការណ៍ខាងលើៗ គេមានហើយលោកក្មួយ ប៉ុន្តែវាទៅមិនរួចវើទៅមិនរួចបានស្ថិតនៅសភាពទប់ទល់ចឹង ក្នុងនាមទប់ទល់គ្នាទៅវិញទៅមកៗអត់មានបានរុលទៅមុខទៀតចឹងទៅ ។

ដារ៉ា ៖ ពេលហ្នឹងបើតាមស្ដាប់ពូមានប្រសាសន៍ហ្នឹងគឺថាយន្តហោះវាមកទំលាក់ខ្លាំង គួរតែមានផែនការមានយុទ្ធសាស្ត្រយ៉ាងម៉េចដើម្បីកំទេចមូលដ្ឋានទ័ពអាកាស?

ជឿន ៖ ហូស! កំទេចអត់បានទេមូលដ្ឋានវានៅលើចេះយើងនៅក្រោមចេះមានតែពួកនៅក្នុងត្រង់សេអត់ចុះផង សិតតែទឹកខែវស្សាឡើងទឹកចេញត្រង់ណា អត់ជីកក៏វាចេញដែលទឹកនៅស្រុកនោះវេទនា ។

ដារ៉ា ៖ ចឹងពេលហ្នឹងកងពូមានការស្លាប់មានរបួសអីដែរ?

ជឿន ៖ ការស្លាប់រស់វាធម្មតា ហើយការធ្វើសង្គ្រាមវាត្រូវតែមាន ហើយទោះបីចង់មិនចង់វាត្រូវតែមានប្រៀបដូចយើងបាយទឹកដាក់គ្នាចឹង បើមិនដល់ស្លាប់ក៏ត្រឹមរបួសដែល ។

ដារ៉ា ៖ របួសស្លាប់ហ្នឹង តើដោយសារការទំលាក់...?

ជឿន ៖ កប៉ាល់ហោះទំលាក់ត្រូវក៏មាន ការបាញ់គ្នាត្រូវក៏មាន ។

ដារ៉ា ៖ មានបាញ់តទល់គ្នាទេ?

ជឿន ៖ មានដូចត្រង់សេ វាទាហានចម្ងាយផ្ទះខាងលិច ហើយត្រង់សេយើងគ្រាន់តែក្នុងដីដូចគ្នាពេលចៃដន្យយើងដើបមិនបានប្រុងប្រយ័ត្ន គេដាក់មកត្រូវដោះទាហានវាមិនបានប្រុងប្រយ័ត្នយើងក្រឡេកទៅឃើញពិនិត្យទៅ ឃើញដាក់ទៅត្រូវវាមិនទៀង ។

ដារ៉ា ៖ ចឹង ចង់និយាយត្រង់សេសិតតែនៅទល់មុខគ្នា?

ជឿន ៖ បាទ! នៅទល់មុខគ្នាចឹង បើយើងធ្វើឃ្លាតឆ្ងាយពីគ្នាកប៉ាល់ហោះទំលាក់ កិនផាប់អស់ ឥឡូវកប៉ាល់ហោះទំលាក់ខ្លាំងណាស់ នៅជិតគ្នាហ្នឹងនៅមានភ្លាត់វាទំលាក់ត្រូវទៀតណា ។

ដារ៉ា ៖ ត្រូវគ្នាឯងហ្នឹង?

ជឿន ៖ បាទ! ហើយជួនកាលវាទំលាក់ចូលគ្នាវាក៏មានដែរ ។

ដារ៉ា ៖ ចឹងមានន័យថា កងទ័ពទាំងពីរនៅទល់មុខគ្នាតែវានៅកៀកគ្នា?

ជឿន ៖ កៀកគ្នាមែនទែន ។

ដារ៉ា ៖ ប្រសិនជាឆ្ងាយគ្នាអាចយន្តហោះទំលាក់នេះជាយុទ្ធសាស្ត្រយោធាពូណោះ?

ជឿន ៖ បាទ!

ដារ៉ា ៖ ប្រសិនជានៅកៀកគ្នាចឹងយន្តហោះទំលាក់មកវាតែងត្រូវគ្នាឯងចឹងដែល...?

ជឿន ៖ បាទ ជួនធ្លាក់ដាក់គ្នាវាជួនធ្លាក់មកលើយើង ប៉ុនភាគច្រើនខាងក្រោយ ខាងក្រោយយើង ។

ដារ៉ា ៖ ប្រសិនជាចំខាងចលនាខ្មែរក្រហមនេះក៏ត្រូវខាង លន់ នល់ ដែរណោះ?

ជឿន ៖ ចំខ្វះដែលហ្នឹងហេតុស៊ិយដូនកាលលែងមកចំម៉ាត្រង់សេ ពីរត្រង់សេចឹងទៅក៏មាន ។

ដារ៉ា ៖ ហើយកាលដែលត្រៀមចឹងមានដែលចាប់បានទាហាន លន់ នល់ ទេ?

ជឿន ៖ អត់ទេ តែត្រៀមទល់មុខគ្នាចឹងវាមិនឲ្យចាប់ទេលោកក្មួយអត់ទេ មានតែការបាញ់គ្នាទៅវិញទៅមកទេ បើគិតបុណ្យបាបអីមានការបាញ់គ្នាទៅវិញទៅមកហ្នឹង បើយើងមិនបាញ់គេ គេបាញ់យើង ។

ដារ៉ា ៖ អាហ្នឹងទាហានវាចឹងហើយណា?

ជឿន ៖ បាទ!

ដារ៉ា ៖ គ្រាន់តែថាពិនិត្យក្នុងទាហានមានច្បាប់ទាហានដែរ ប្រសិនយើងចាប់បានឈ្លើយសឹកអីចឹងគេមិនឲ្យយើងសម្លាប់ឈ្លើយសឹក មិនឲ្យយើងធ្វើអីចឹងណា តើក្នុងពេលហ្នឹងមានចាប់ចឹងដែរអត់?

ជឿន ៖ អត់ទេ! អាហ្នឹងលុះត្រាតែអីចេះលុះត្រាវៃបុកទៅវៃសំរុកគ្នាទៅវិញទៅមកអាហ្នឹងអាច បើថាទល់ត្រឹមខ្សែត្រៀមចឹងអត់ទេ ។

ដារ៉ា ៖ ចឹងពូត្រៀមនៅកន្លែងហ្នឹងបានរយៈពេលយូរទេ?

ជឿន ៖ ១ឆ្នាំទៅកន្លែងហ្នឹងគេសំរាប់ទប់ពួកទាហានហ្នឹង១ឆ្នាំគត់ ។

ដារ៉ា ៖ ក្រោយពីទប់បាន១ឆ្នាំហើយបែកភ្នំពេញឬមួយយ៉ាងមេច?

ជឿន ៖ គេដកមកកំពតវិញ ដើម្បីគេលើកទិសវៃផ្តាច់ភ្នំពេញ យើងលើកទិសវៃផ្តាច់តាមខេត្ត ។

ដារ៉ា ៖ ចឹងវិញ?

ជឿន ៖ បាទ!

ដារ៉ា ៖ ពេលលើកមកកំពតហ្នឹងកងពូទាំងមូលតែម្តងយ៉ាងម៉េច?

ជឿន ៖ មកទាំងអស់ ដាច់ដោយឡែកគេដកឡើងទៅភូមិភាគនោះ៣អនុសេនាតូច នៅតែ១អនុសេនាតូចទេមកនេះមករៀបជាវរសេនាតូចមួយទៀត រើសកម្លាំងពីក្រោយទៅដាក់ថែមមកទៀត ។

ដារ៉ា ៖ ដកម៉ាអនុសេនាតូចហ្នឹងគឺក្នុងហ្នឹងមានពូដែរដែលត្រូវដកមកកំពតហ្នឹង?

ជឿន ៖ បាទ! ៣អនុសេនាតូចគេយកទៅនោះ គេយកទៅភ្នំពេញគេយកទៅឡើងភូមិភាគគេនោះ

ដារ៉ា ៖ ហើយ១អនុសេនាតូចដែលត្រូវដកមកកំពតវិញមានពូដែរ?

ជឿន ៖ បាទ!

ដារ៉ា ៖ ចុះក្នុងហ្នឹងពេលដែលចូលដល់អនុសេនាតូចអីចឹង ដល់កងវរសេនាតូច៥១ចឹង ហើយមកត្រៀម ដល់កេងកងទីតាំងជិតទ័ពអាកាសរបស់ លន់ នល់ អីចឹងពូមានទទួលបានតួនាទីអីទេ?

ជឿន ៖ អត់ទេ! គេឲ្យខ្ញុំធ្វើនិរសាររហូត និរសារគេអត់ដែលបានទទួលតួនាទីអីគេទេ គេឲ្យស្ពាយតេអូតេវ៉ាំងសែនពីក្រោយរហូតហ្នឹង ។

ដារ៉ា ៖ និរសាររបស់អ្នកណា?

ជឿន ៖ និរសារ ដល់មកកំពតហ្នឹងវិញគេឲ្យនិរសារ តាឆៃ ហួស! តាចិន កាលពីមុននិរសារតាឆៃដល់ តាឆៃ គេដកឡើងទៅភូមិភាគទៅខ្ញុំនៅនិរសារ តាចិន ។

ដារ៉ា ៖ ម៉ារយៈពេលដែលពូទៅធ្វើទ័ពនៅកងវរសេនាតូចលេខ៥១ហ្នឹងពូជានិរសាររហូតចុះ?

ជឿន ៖ បាទ! ជានិរសាររហូតដល់ពេលរត់ហ្នឹងម៉ង បានឈប់បែកគ្នាអស់និរសារ តារិន ទៀតក៏ខ្ញុំធ្វើនិរសាគេ ។

ដារ៉ា ៖ ចឹងម៉ារយៈពេលដែលធ្វើនិរសា តាឆៃ តាចិន នេះពួកខ្មែរក្រហមវ៉ៃបានភ្នំពេញឬនៅ?

ជឿន ៖ នៅទេមិនទាន់បានទេ ។

ដារ៉ា ៖ ពេលដកមកកំពតវិញបានប៉ុន្មានឆ្នាំបានបែកភ្នំពេញ?

ជឿន ៖ បានប្រហែល១ឆ្នាំ ១រដូវ គ្រាន់តែសំរាកបន្តិចហើយលើកទិសវ៉ៃផ្តាច់ព្រាត់ជ័យជម្នះហ្នឹងម៉ង

ដារ៉ា ៖ ពេលមកដល់កំពតពូនៅម្តុំណាមូលដ្ឋាន?

ជឿន ៖ ម្តុំគេហៅ...ភូមិតាអេង ម្តុំវត្តសុវណ្ណសាគរ ម្តុំខាងត្បូងវត្តសុវណ្ណសាគរ ។

ដារ៉ា ៖ ភូមិអីគេមិញ?

ជឿន ៖ ភូមិតាអេង វត្តសុវណ្ណសាគរ ។

ដារ៉ា ៖ ម៉េចបានជាចូលចិត្តយកវត្តធ្វើជាមូលដ្ឋាន?

ជឿន ៖ អត់មាននៅក្នុងវត្តទេគ្រាន់តែវត្តពួកទាហានកាន់កាប់បេះខ្ញុំនៅខាងត្បូងអីបេះ ។

ដារ៉ា ៖ នៅជុំវិញៗនៅក្បែរៗហ្នឹង?

ជឿន ៖ បាទ! ទាហានគេនៅក្នុងវត្តនៅយើងខាងៗវត្តទៅ ដូច្នេះជាគោលដៅដែលយើងស្គាល់មានតែនៅខាងត្បូងវត្តសុវណ្ណសាគរហ្នឹង បើទាហានវាំនៅក្នុងវត្តសុវណ្ណសាគរហ្នឹងទៅ ។

ដារ៉ា ៖ ហើយពេលហ្នឹងដូចថា អត់ទាន់បានវ៉ៃបែកភ្នំពេញទេ?

ជឿន ៖ នៅទេ ហ្នឹងគេលើកទិសវ៉ៃផ្តាច់ហើយ ដល់គេវ៉ៃផ្តាចម៉ងដល់គេលើកទិសវ៉ៃកំពតក៏វ៉ៃភ្នំពេញក៏វ៉ៃ ហើយខ្ញុំត្រូវគ្រាប់គេឲ្យធ្វើនិរសារសមរភូមិត្រូវគ្រាប់ខ្ញុំសន្លប់ បាត់លែងដឹងរហូតចំនួនប្រហែល៣, ៤ខែដេកពេទ្យ ។

ដារ៉ា ៖ ត្រូវរបួសហ្នឹងនៅក្នុងពេលវៃផ្កាច់ព្រ័តយកខេត្តកំពតហ្នឹងហេ?

ជឿន ៖ បាទ! ពេលវៃយកហ្នឹងតែមិនទាន់បានទៀត ដល់ខ្ញុំចេញពីពេទ្យបានប្រហែល១ខែបានបាន ជ័យជម្នះ ។

ដារ៉ា ៖ ជ័យជម្នះនៅខេត្តកំពតហ្នឹងហេ?

ជឿន ៖ បាទ! ខ្ញុំដេកពេទ្យ៣ខែមិនដឹងម៉េចៗទេពេលហ្នឹងព្រោះខ្ញុំសន្លប់មិនដឹងខ្លួនកន្លះខែអត់ដឹងផង ។

ដារ៉ា ៖ បែកខេត្តកំពតពេលបែកដំបូងហ្នឹងពូបានឃើញទិដ្ឋភាពដាក់ស្ដែងពេលបែកចូលដំបូងទេ?

ជឿន ៖ ខ្ញុំអត់សូវបានដើរមើលគេទេលោកក្មួយព្រោះខ្ញុំជាប់កាន់អាតេអូហ្នឹង ដឹងថាគេដាក់នៅកន្លែងណា ដូចនៅផ្ទះមួយចឹងនៅក្នុងផ្ទះហ្នឹង សំរាប់ទាក់ទងសំរាប់ចាំទទួលគេ និយាយចូលមកដូចគេត្រូវឲ្យនិយាយចេញទៅ អត់មានទេខ្ញុំដឹងតែកាន់ម៉ាថ្ងៃៗដឹងតែអង្គុយ ដូចអាអូនឯងចឹងគេអូនៅនឹងមុខអីចឹង គេអូខ្សែគេអូខ្យល់ខ្ញុំនៅចាំតែទទួលគេដូចជា មានកិច្ចការអីចាំបាច់ទៅប្រាប់មេបញ្ជាការគេទៅ ។

ដារ៉ា ៖ ចឹងអាតេអូហ្នឹងវានៅកៀកជាប់ជាមួយមេបញ្ជាការម៉េងបុយ៉ាងម៉េច?

ជឿន ៖ បញ្ជាការ ប៉ុន្តែខ្ញុំជាអ្នកកាន់ៗ ឧទាហរណ៍ មេបញ្ជាការគេត្រូវមានការអីគេត្រូវទៅណាមក ណាអី អត់មានទូរស័ព្ទដៃដូចនៅចន្លោះអីណាទេ ដល់ទៅហៅគេមកដល់គេមកប្រាប់ហេតុផល គេ គេទាក់ទងគ្នាគេទៅ ។ ដូចគេចង់ជួបអូនឯងមេបញ្ជាការអីចឹងប្រៀបធៀបណាគេចង់ជួប អាអូនឯងចឹង ខ្ញុំត្រឹមបានទទួលហុចអាដៃមេគ្រូ ហួស! អាដៃទូរស័ព្ទចឹងកាលពេលមុនគេហៅ ថាកុំម្ទេ ហុចដៃកុំម្ទេឲ្យអាអូនឯងចឹងទៅមេបញ្ជាការហ្នឹង ខ្ញុំដើរចេញបានគេទទួល ធូរចិត្ត បន្តិច យើងមិនសូវបានអង្គុយដែរហ្នឹងបើមិនចឹងនៅតែអង្គុយ ។

ដារ៉ា ៖ ភាគច្រើនពូពេលដែលទទួលតេអូចូលមកហ្នឹងច្រើនពីខាងណាមក?

ជឿន ៖ គេទទួលភូមិភាគទូទៅរួមម៉ាខេត្តកំពត តាកែវ កំពង់ស្ពឺ កោះកុង ៤ខេត្តហ្នឹង តែគេចង់ជួប ដូចអាអូនមេបញ្ជាការដូចខ្ញុំបានជំរាបអីចឹង ហុចតែដៃកុំម្ទេទៅឲ្យអាអូនឯងមេបញ្ជាការហ្នឹង ខ្ញុំ ដើរទៅជុះអាចម៍ជុះនោមឯណោះ អត់មានបាននៅយកចិត្តទុកដាក់ស្ដាប់អី គេទេបន់ឲ្យតែគេ បានទទួលទៅអរចង់ស្លាប់ហើយវាបានរំសាយខាងផ្លូវចិត្តយើងណា រំសាយខ្លួនយើងបានដើរទៅ នេះទៅនោះម៉ាភ្លេចថាដកឃ្លាពីការងារ ។ ហើយបើថាអត់ទេនៅតែអង្គុយចាំស្ដាប់ចឹងដាក់អា បំពងសម្លេងហៅថាដៃថុងបាស់ប៉ុណ្ណឹង ៤ជ្រុងលីប្រហែលយើងនិយាយគ្នាប៉ុណ្ណឹង ។

ដារ៉ា ៖ ភាគច្រើនពូទំនាក់ទំនងមកពីខាងណា ចូលមកតេអូរបស់ពូកាន់?

ជឿន ៖ អត់ទេ អត់ឃើញអ្នកធំអ្នកតូចណាទេ ។

ដារ៉ា ៖ ភាគច្រើនហៅមកពីខាងណា?

ជឿន ៖ ហៅ? វាអីចេះទេលោកក្មួយរឿងហៅហ្នឹងវាតាមអារម្មណ៍ឯងបញ្ហាការខាងកោះកុងឬបញ្ហាការខាងកំពត ខាងតាកែវចឹងអីត្រូវការខ្ទះខាតអីចឹងណា គេរាយការណ៍មកថាខ្វះខាតអីខ្ញុំប្រាប់ថាខ្វះខាតនេះខ្វះខាតនោះ មេបញ្ហាការគេចាត់ចែងទៅខ្ញុំត្រឹមតែហុចផ្ញើមេក្រូផ្ញើកុំម្មេនោះ ឲ្យទេបើឲ្យខ្ញុំចាត់ចែងអត់ទេ ។

ដារ៉ា ៖ ហុចៗហើយគ្រាន់ថាការទាក់ទងភាគច្រើន វាទូទៅចូលមកខេត្តទាំង៤ពូរៀបរាប់មិញហ្នឹង?

ជឿន ៖ បាទ វាទូទៅ ។

ដារ៉ា ៖ ភាគច្រើនបញ្ហាអីដែលគេទាក់ទងមក?

ជឿន ៖ ទាក់ទងឲ្យខ្ញុំដឹងម៉ងរឿងស្បៀង រឿងខោអាវ រឿងបារីជក់ រឿងគ្រាប់ រឿងកាំភ្លើង បើថាឲ្យរឿងអីផ្សេងៗ គ្រាន់តែគេសុំជួបបញ្ហាការបន្តិចហុចឲ្យគេទៅយើងដើរចេញ ។

ដារ៉ា ៖ ការដើរចេញជាការ...ចង់និយាយថាមេបញ្ហាការអត់ឲ្យយើងនៅជាប់?

ជឿន ៖ មិនមែនទេ គេឲ្យយើងនៅដែរហ្នឹង តែយើងមិននៅ ខ្ជិល ចុះបើអង្គុយអីចឹងតែរហូត ។

ដារ៉ា ៖ ជួនកាលយើងចង់ដឹងពីរឿងរ៉ាវដែលគេទាក់ទងគ្នាអ្នកធំៗណា?

ជឿន ៖ អត់ចង់ ធុញម៉ងលឺតែកោកៗធុញម៉ង ដូចអារម្មណ៍ឯងចឹងអង្គុយសរសេរយូរធុញបើមានបានលទ្ធផលទៅវាអត់ធុញទេ ចុះបើវាអត់បានលទ្ធផល ដល់យើងសោះផងបានត្រឹមតែអង្គុយស្ដាប់ហ្នឹង បានលទ្ធិផលអីធុញរត់ទៅលេងបាល់វ៉ៃបាល់ ។

ដារ៉ា ៖ ចុះអ្នកកាន់គេអូៗដូចគ្នានៅខាងផ្សេង ដែលយើងអត់មានទំនាក់ទំនងនិយាយគ្នាបានទេ?

ជឿន ៖ ទំនាក់ទំនងនិយាយលេង យើងបានត្រឹមនិយាយលេងនិយាយលេងចេះមួយចេះពីរ បើឲ្យនិយាយពីការងារអី យើងគ្មានសិទ្ធិទេយើងគ្រប់គ្នានោះ យើងគ្រប់គ្នាសារគេ យើងគ្មានសិទ្ធិទេ ។

ដារ៉ា ៖ ភាគច្រើនពេលរាយការណ៍តាមគេអូចឹងមានកត់ត្រាទុកទេពូ?

ជឿន ៖ អត់ទេ គេអត់ឲ្យរាយការណ៍តាមគេអូទេ ។

ដារ៉ា ៖ ធ្វើមេចទៅ?

ជឿន ៖ ចារជាលិខិតគេហ្នឹង គេមាននិរសារត់ការគេផ្សេង ឡានគេផ្សេង ម៉ូតូគេផ្សេង ដូចថានិរសាខាងរត់ការដូចថា គេនិយាយគ្នាហើយគេសរសេរជាលាយលក្ខអក្សរ ហើយគេដាក់ស្រោមសំបុត្របត់ពិបចឹង អារម្មណ៍នេះខាងនិរសាខាងរត់ការ ភ្លែតគេហុចទៅអារម្មណ៍ហ្នឹងចឹង ទៅម៉ូតូឡើងព្រៃន ឬក៏ឡានគេឡើងព្រឹន ទៅគេទៅទៅមិនដឹងគេទៅណា យើងអត់ដឹងតួនាទីកាន់

គេអូហ្នឹង អត់មានអាចដឹងរឿង អត់ចឹងដឹងផង បើចង់ដឹងនាំគេប្រើនិយាយចេះវិញ ឆាប់ស្ដាប់បាន ។

ដារ៉ា ៖ ពូរៀបរាប់មិញហ្នឹង ភាគច្រើនការទាក់ទងតាមគេអូហ្នឹង ភាគច្រើនពីរឿងការខ្វះខាតស្បៀង?

ជឿន ៖ បាទ! ស្បៀង គ្រាប់ សំលៀកបំពាក់ ម្ហូប

ដារ៉ា ៖ អាហ្នឹងសំរាប់តែរឿងទ័ពឬក៏ទូទៅជាប្រជាជនអីដែល?

ជឿន ៖ រឿងទ័ពនិយាយតែរឿងទ័ពទេ បើនិយាយប្រជាជនអាហ្នឹង ដោយឡែកផ្សេងជារឿងរបស់គេរឿងប្រជាជនមានថ្នាក់ទទួលខុសត្រូវគេផ្សេង ខាងកន្លែងខ្ញុំទទួលខុសត្រូវតែពីរឿងទ័ព ។

ដារ៉ា ៖ តើពួកទ័ពនិងប្រជាជនធម្មតានៅយ៉ាងមេចដែរ?

ជឿន ៖ ចេះលោកក្មួយរឿងទ័ពម៉ាកំណាត់ខាងជួរក្រោយទ័ពហ្នឹង គេត្រៀមសង្គ្រាមរហូត គេអត់ឲ្យប្រជាជននៅជិតទេ ដីប្រហែល១០គីឡូពីទ័ពហ្នឹង ដាច់ខាងអត់មានប្រជាជនទេ ដូច្នេះការទំនាក់ទំនងគ្នាអីអត់ទេ លឺខ្ញុំជំរាបអូនខាងដើមទេ តាំងពីទៅសង្គ្រាមមកបានមកលេងស្រុកម្ដងទេ ម្ដងហ្នឹងដូចជាអត់បានដេកផង អឺហ៉េ!ដូចអត់បានសំរាន្តនៅផ្ទះម៉ាយប់ផងអត់ទេ ។

ដារ៉ា ៖ ចុះមោលេងចឹង បញ្ហាការគេចេញសំបុត្រស្នាមឲ្យមកលេងយ៉ាងមេច?

ជឿន ៖ អត់បាច់ចាំសំបុត្រទេ មនុស្សមកដល់ស្រុក ហើយគ្រាន់តែដើរមកដល់ស្រុកហ្នឹង អរចង់ប្រកាច់ទៅហើយ អាឡូចាំសំបុត្រចាំស្នាមគេធ្វើលិខិត កាលពីមុនគេអត់មានលិខិតទេ ។

ដារ៉ា ៖ ពេលដែលពូមកលេងស្រុកភូមិពូបានម្ដងហ្នឹង ពូមានសង្កេតឃើញនៅក្នុងស្រុកភូមិពូយ៉ាងមេចទៅ?

ជឿន ៖ គេមិនចង់ឲ្យបាយហូបផង គេអត់មានទឹករឿងអី ។

ដារ៉ា ៖ ហើយបានជួបបងប្អូនឪពុកម្ដាយទេ ពេលកាលមោហ្នឹង?

ជឿន ៖ ជួបបង ឪពុកម្ដាយខ្ញុំ តែវាចេះអត់ជួបប្អូនធ្វើទ័ពថាទៅបាត់ដើងទឹកអីហ្នឹង ខ្ញុំអ្នកកាន់គេអូសួររកទូទាំងប្រទេសរកអត់ឃើញ អត់មានលឺគេអូរាងលើកអង់តែនអាឆ័តខ្ពស់ធំយើងអាចទាក់ទងបានទូទាំងប្រទេស ប៉ុនសួរគ្រប់ខេត្តអត់ឃើញសាប់បាត់ទៅបានរកអត់ឃើញ ។

ដារ៉ា ៖ ចឹងកាលហ្នឹងពូធ្លាប់ទំនាក់ទំនងតាមគេអូសួររកប្អូនពូដែល?

ជឿន ៖ បាទ! សួរ ។

ដារ៉ា ៖ ដូចកំពត កំពង់សោមអីវានៅចង្កោមជាមួយគ្នាតើពូអី?

ជឿន ៖ បាទ  បើយើងចង់ដឹងទៅខេត្តផ្សេងៗទៀតខាងបាត់ដំបង  កំពង់ឆ្នាំងអីចឹងទៅយើងសួរតាមរយៈខេត្តដែលជាប់គ្នាចឹង  ទៅម៉ូគេលេខម៉ានៗយើងចុចសួរគេទៅ  ដូចអាទូរស័ព្ទដៃយើងចឹងណា ។

ដារ៉ា ៖  កាលហ្នឹងពេលដែលសួរតាមគេអូហ្នឹង  អត់មានដំណឹងសោះដំណឹងប្អូនរបស់ពូ  គេអត់ស្គាល់ឬយ៉ាងមេច?

ជឿន ៖ មិនដឹងអត់ស្គាល់ទេ  ឬក៏អត់ឮឃើញឈ្មោះហ្នឹង  គេនិយាយចឹងចប់  ហើយយើងមិនដឹងទៅសួរពីណាទៀតវា  អត់ឃើញហើយអត់ឮឈ្មោះហ្នឹងទៀត ។

ដារ៉ា ៖  ប្អូនពូដែលទៅទ័ពខាងជើងទឹកទៅពីពេលណា?

ជឿន ៖ ខ្ញុំទៅបាត់ហើយ២ឆ្នាំហើយ  វាក្មេងតូចក្រោយណាគេហៅកងកុមារ  គនោះគេឡើងទៅបាត់រហូត ។

ដារ៉ា ៖  ពេលពូទៅធ្វើទ័ពនោះពូដឹងដំណឹងថាប្អូនពូទៅទ័ពជើងទឹកតាមរយៈណាទៅ?

ជឿន ៖ រឿងរយៈកាលហ្នឹង  វារយៈមិនឃើញទេ  លោកក្អួយខទាហរណ៍គេបញ្ជូនតាមកងកុមារហ្នឹងទៅគ្រូទៅបាត់ហើយអត់ដឹង ។

ដារ៉ា ៖  ធ្វើមេចបានពូដឹងថាទៅ..?

ជឿន ៖ ដឹងបេះដឹងតាមរយៈម្ដាយខ្ញុំ  គាត់ប្រាប់ខ្ញុំពេលខ្ញុំមកលេងផ្ទះ ។

ដារ៉ា ៖  ពេលដែលមកលេងផ្ទះម្ដងហ្នឹង?

ជឿន ៖ បាទ!  ថាទៅជើងទឹកដឹងតែប៉ុណ្ណឹង  មានដឹងតាប៉ុណ្ណឹង ។

ដារ៉ា ៖  ចុះម៉ារយៈពូពេលខ្មែរក្រហមវ៉ៃបានកាន់កាប់បានក្រុងភ្នំពេញ  ហើយកន្លែងពូវ៉ៃកាន់កាប់នៅខេត្តកំពតរបស់ពូ?

ជឿន ៖ នៅតែនិរសារគេដដែលហ្នឹង ។

ដារ៉ា ៖  នៅតែនិរសារដែលចង់និយាយថា  រយៈពេលខ្មែរក្រហមគ្រប់គ្រងអំណាចពីឆ្នាំ៧៥-៧៩  តើការងាររបស់ពូដែលកាន់គេអូហ្នឹង  វាធ្វើការងារអីបន្តទៅទៀតទៅ?

ជឿន ៖ អត់មានអីបន្តមាននៅតែកាន់តែប៉ុណ្ណឹង  គេឲ្យកាន់តែប៉ុណ្ណឹង  ខ្ញុំដឹងកាន់តែប៉ុណ្ណឹងអត់មានធ្វើអីក្រៅពីណឹង  នៅតែណឹងគេថាយើងបេះអាណឹងឲ្យទៅធ្វើអីទៀត  អត់មានមុខការធ្វើ ។

ដារ៉ា ៖  ពូមានបានទៅរៀនសូត្រ  ឬវគ្គបំពាក់បំប៉នណាគេអូទេ?

ជឿន ៖ វគ្គបំពាក់បំប៉នគ្មានទេ  អត់ទាល់តែសោះ ។

ដារ៉ា ៖ ពេលក្នុងកំឡុងពេលណឹង ពេលដែលបែកភ្នំពេញ ហើយកំពតក៏បែកដែលចឹង ខ្មែរក្រហមក៏កាន់កាប់ភូមិស្រុកណោះ ពូនៅពេលណឹង?

ជឿន ៖ បាទ! កាន់កាប់ហើយពិត ណឹងគេយកទៅដាក់នៅព្រំដែននៅភ្នំលក ។

ដារ៉ា ៖ ពេលដែលវៃបានកំពតហើយកងពូគេយកទៅដាក់នៅណាវិញ?

ជឿន ៖ នៅព្រំដែននៅភ្នំលកគេឲ្យប្រកបកសិកម្មធ្វើស្រែធ្វើចំការ ហើយនៅភ្នំណឹង ហើយធ្វើស្រែនៅជុំវិញចំការណឹង ។

ដារ៉ា ៖ ហៅថាភ្នំលកចឹងម៉ងហេ?

ជឿន ៖ បាទ!

ដារ៉ា ៖ នៅម្តុំណា?

ជឿន ៖ ម្តុំជាប់វៀតណាមណឹង ។

ដារ៉ា ៖ នៅក្នុងទឹកដីខេត្តកំពតដែល?

ជឿន ៖ បាទ! ទឹកដីខេត្តកំពតដែលណឹង ។

ដារ៉ា ៖ ភាគខាងណា?

ជឿន ៖ ភាគខាងត្បូងជាប់ព្រំដែនវៀតណាមណឹង ម៉ងជាប់មើលឃើញគ្នាទៅវិញ ទៅមកគោស៊ីក្របីស៊ីឆ្លងគ្នា ទៅវិញទៅមកណឹងណា ។

ដារ៉ា ៖ ហើយនៅម្តុំណឹង ពូកាន់គេអូដ៏ដែលទៀត?

ជឿន ៖ បាទ នៅកាន់តែអាណឹងគេឲ្យកាន់តែអាណឹង

ដារ៉ា ៖ តើម៉ាថ្ងៃៗពូស្តាប់បានកិច្ចការងារអីខ្លះទៅតាមរយៈគេអូ?

ជឿន ៖ ដូចខ្ញុំនិយាយចឹង តែការងារសំខាន់គេអត់ឲ្យយើងដឹងទេ ពួកអ្នកកាន់បើការងារសំខាន់គេជួបគ្នាគេខាងធំៗណឹង ទៅបើការងារយើងនិយាយលេងតាមគ្នា យើងទាក់ទងគ្នាយាយទៅធម្មតាគ្មានរឿងអី បើការងារសំខាន់ៗគេអត់ឲ្យយើងដឹងទេ ។

ដារ៉ា ៖ ចឹងពូនៅកន្លែងភ្នំលោករហូតដល់?

ជឿន ៖ នៅវៃយួននៅភ្នំលក ។

ដារ៉ា ៖ វៀតណាមចូលមក៧៩ណឹងហេ៎?

ជឿន ៖ បាទ! យួនវៃគ្នាវៃគ្នាជិហិតជិហូមនៅណឹង

ដារ៉ា ៖ ទប់ទល់តាមព្រំដែនណឹងហេ?

ជឿន ៖ បាទ!

ដារ៉ា ៖ ពេលវ៉ៃគ្នាចឹង មានការវ៉ៃគ្នាជាមួយវៀតណាមចុះឡើងៗចឹង ខាងគេអូរាយការណ៍ទៅណា?

ជឿន ៖ គេអូ នៅតែកាន់គេអូដដែលណឹង ។

ដារ៉ា ៖ ចង់និយាយពេលមានសភាពការចឹង ពេលវ៉ៃជាមួយវៀតណាមចុះឡើងៗចឹង ណាកន្លែងគេអូពូភាគច្រើនច្រើនរាយការណ៍ទៅខាងណា រាយការណ៍ចេញទៅខាងណា?

ជឿន ៖ មានតែទាក់ទងទៅសមរភូមិមុខ ដូចថាទៅកងនេះៗកងនោះ តាមព្រំដែនចឹងមានឲ្យទៅអីណា បើរៀងចេញពីខេត្តមេបញ្ជាការគេទៅជួបគ្នា ឧទាហរណ៍ចេញពីខេត្តកំពតនេះទៅខាងខេត្តកោះកុង គេចង់ជួបអីជួបជាមួយបញ្ជាការពីប កំពង់ស្ពឺចង់ជួបអីជួបជាមួយបញ្ជាការពីប ខាងតាកែវចង់ជួបជួបជាមួយបញ្ជាការពីប យើងអត់មានសិទ្ធិទេ យើងបានតែត្រឹមហុចដូចខ្ញុំប្រាប់ចឹង ប្អូនឯង ។

ដារ៉ា ៖ ចុះពេលមេបញ្ជាការត្រូវដាក់បទបញ្ជាអី ទៅតាមកងនៅក្នុងខេត្តដែលអាណឹងធ្វើមេច?

ជឿន ៖ បទបញ្ជាយុទ្ធនាការអីអាណឹង គេហៅមេៗគេមោប្រជុំមកដូចថាមេបញ្ជាការវរៈ៥១ វរៈ៥៣ វរៈ៥៥ វរៈ៥៧អីចឹងគេមកធ្វើវិធីប្រជុំគ្នាណឹង គេលើកទិសទៅយើងបានទូលាយខាងផ្លូវចិត្តដើរទៅលែងបាល់ ។

ដារ៉ា ៖ មុននឹងបានការជុំគ្នាចឹង មិនមេបញ្ជាការមកខាងគេអូប្រាប់ឲ្យទាក់ទងទៅតាមអង្គភាពចឹងហេ?

ជឿន ៖ ការគោរពអញ្ជើញគេសរសេរលិខិត គេអត់និយាយតាមគេអូទេ គេសរសេរតាមលិខិតនិរសាខាងរត់ការគេយកទៅផ្ទាល់ៗយើងនេះអត់និរសារគេលាក់ការណ៍គេអត់ឲ្យយើងដឹងទេ

ដារ៉ា ៖ អាគេអូណឹងវាខុសគ្នានិងទូរលេខពូហេ?

ជឿន ៖ ទូរលេខផ្សេង ទូរលេខសំរាប់ទាក់ទងគ្នា ខ្ញុំក៏គេឲ្យកាន់ដែលខាងទូរលេខណឹង កាន់ទូរលេខបានប្រហែលជា៣ខែបានរត់ចោលអស់ គេឲ្យខ្ញុំកាន់ណាទូរលេខ អង្គុលីលេខ គេអូខ្យល់ គេអូខ្សែ ៨ណឹងគេឲ្យខ្ញុំកាន់៨ណឹង ។

ដារ៉ា ៖ ពូមានប្រសាសន៍មិញថា កាន់អាទូរលេខណឹង បាន៣ខែចុងក្រោយបានបែក?

ជឿន ៖ បែកគ្នារត់យ៉ៃយ៉ៃចោល អាសម្ភារៈណឹងអស់ទៅមិនដឹងទៅណាទៅ ។

ដារ៉ា ៖ អាទូរលេខណឹងពេលទទួលមក យើងវ៉ៃព័ត៌មាន ដាក់លើជាលិខិតក្រដាស់អីផ្ញើទៅ ប្តុយ៉ាងមេច?

ជឿន ៖ វាចេះទេទូរលេខណឹង លោកក្លួយដូចថាវាចុចមកគេតៗឃើញតែលេខទេ ហើយយើងកត់ត្រាមកលេខ២ លេខ៣ ៥ ៦ ១០ ១២ ៣៣ ៣២ ៣៤ ៣១ ចឹងទៅដល់ពេលយើងយកមករាបជាអក្សរ ការទំនាក់ទំនងដាក់ម៉ូគ្នា ឧទាហរណ៍អក្សរកគេដាក់ប៉ុន្មាន? ដាក់លេខ៥

អក្សរខដាក់លេខប៉ុន្មាន? ដាល់លេខ៣អក្សរឥដាក់លេខប៉ុន្មាន? ដាក់លេខ៧ គេកំណត់គ្នាដាក់ម៉ូគ្នាចឹង គេអត់មានដាក់កលេខ១ ខលេខ២អី ។

ដារ៉ា ៖ ចឹងពេលដែលយើងទទួលបានជាលេខហើយយើងផ្ដុំទៅជាអក្សរ?

ជឿន ៖ បាទ! ផ្ដុំជាអក្សរផ្ដុំហើយឲ្យទៅបញ្ជាការ គេទៅគេរាយរាបជាអក្សរចឹង ឲ្យទៅបញ្ជាការគេទៅយើងបានដឹងតែប៉ុណ្ណឹង ។

ដារ៉ា ៖ ម៉ារយៈចុងក្រោយ៣ខែ ពូកាន់ទូរលេខណឹង តើពូសំគាល់ឃើញថាវាមានបញ្ហាអីកើតឡើង?

ជឿន ៖ មានបញ្ហាកុនចេះវិញ ឧទាហរណ៍កុនស្បៀងត្រូវចោទ បញ្ហាស្បៀងត្រូវទាក់ទងទៅចិនដើម្បីផ្ដល់ជំនួយមកតាមរយៈណា១អីយើងរាបជាលេខឃើញចឹងណា យើងយកឲ្យបញ្ជាការគេដល់នេះគេបញ្ជាមកគេសរសេរវិញ ហើយបញ្ជាការគេសរសេរចឹង១ យើងរាបបានជាលេខចុចទៅវិញ ល្មមរាបបានជាលេខចុចទៅវិញ ម៉ាណាត់ព្រឹកឬម៉ាថ្ងៃ បើវែងម៉ាថ្ងៃឬម៉ាព្រឹកវាចឹង ។ ព្រោះគេមិនយកលេខ១អក្សរក លេខ២អងក្សរខ លេខ៣ជាអក្សរគចឹងណា គេអត់យកចឹងទេ គេដាក់លេខ១ជាអក្សរម៉ូ គេដាក់ម៉ូជាតារាងឲ្យយើងមើលជាតារាងទូទៅណា សិតតែម៉ូគេណា ។

ដារ៉ា ៖ ចឹងមួយរយៈក្រោយណឹង ដែលបែកមុនរយៈពេល៣ឬ៤ខែ ពូកាន់ទូរលេខណឹង ពូសំគាល់ឃើញថារឿងស្បៀងវាជាបញ្ហាកុន?

ជឿន ៖ ស្បៀង គ្រាប់ សម្ភារៈវេជ្ជសាស្ត្រ អាណឹងសំខាន់ដឹងយើងទទួលមកសំរាប់រាប សំរាប់គេអត់ចេះណឹងណា អាគេអត់ចេះទទួលទូរលេខរាបជាភាសារាបជាខ្មែររាបអក្សរចឹង គេអត់ចេះគេឲ្យយើងដឹង ហើយអាណឹងដល់យើងអ្នករាបណឹង ដល់នេះគេសរសេរជាអក្សរចឹង ហើយឲ្យយើងរាបជាលេខចុចទៅវិញទៅ ។

ដារ៉ា ៖ ចឹងមានន័យថា ខ្ញុំចង់សង្កត់ធ្ងន់ថា ពេលដែលមានបទបញ្ជាចុះមកតាមខេត្តតាមភូមិភាគអីចឹងពីមជ្ឈិមតាមទូរលេខគេធ្វើតាមបែបណឹងហ៎? ចឹងហើយបានជាយើងឃើញនៅក្នុងឯកសារវាអត់ឃើញជាអត្តលេខា វាអត់ឃើញអីវាអត់មានទេ តែយើងដាក់ឈ្មោះដែរពូ បើសិនជាត្រូវរាយការណ៍ត្រឡប់ទៅវិញ?

ជឿន ៖ បាទ! រាយការណ៍ត្រឡប់ទៅវិញគេដាក់ជាភូមិភាគដូចថាភូមិភាគនិរតី ភូមិភាគនិរតី ។

ដារ៉ា ៖ ចឹងហើយបានជាខ្ញុំសួរសង្កត់ធ្ងន់កន្លែងណឹង ដោយសារខ្ញុំនៅមជ្ឈមណ្ឌលឯកសារកម្ពុជាណឹងក៏មានឯកសារទូរលេខ ដែលពូហើយឯកសារទូរលេខយើងចង់ដឹងថា តើឯកសារទូរលេខណឹងវាទទួលបាន គេធ្វើយ៉ាងមេច១ណា?

ជឿន : ធ្វើចឹង ដូចខ្ញុំជំរាប ។

ដារ៉ា : ចឹងហើយបានឃើញវាអត់មានអត្តលេខទេ?

ជឿន : អត់ទេគេដាក់ដូចថា យើងនិយាយចឹងគេដាក់អត្តលេខាភូមិភាគនិរតីចឹងទៅ ឯគេយកទៅធ្វើមេ ចទៀតយើងអត់ដឹង និយាយឆាប់ចប់ណាព្រោះការងារយើងជានិរសារគេ ហើយយើងខាង ទទួលទូលេខណឹងបានត្រឹមប៉ុណ្ណឹង បន់ឲ្យគេមកអន្តុយអារត់ទៅទាត់សីអីណា ។

ដារ៉ា : ចុះពូពេលដែលបែកខ្ទាត់ខ្ទាយឆ្នាំ៧៩ពេលវៀតណាមវ៉ៃចូលមកចឹងណាពូរត់ទៅខាងណា?

ជឿន : រត់ទៅភ្នំលិច ។

ដារ៉ា : ភ្នំអីគេពូ?

ជឿន : ភ្នំធំភ្នំទៅតាកែនកោះស្លា ត្រពាំងភ្លាំង រោងបារាំងម៉ាជួរណឹងខ្ញុំអត់ទៅណាឆ្ងាយគេទេ ។

ដារ៉ា : ម៉ាម្តុំណឹង?

ជឿន : បាទ!

ដារ៉ា : វ៉ៃមកខាងទ័ពរដ្ឋាភិបាលវិញ?

ជឿន : អត់ដែលបានវ៉ៃអីទេ មានទ័ពរដ្ឋាភិបាលអីណាខ្ញុំចុះមកទ័ពរដ្ឋាភិបាលអត់ទាន់មានទេ ខ្ញុំចុះមក មុនបាត់ ហើយអត់ទាន់មានទ័ពរដ្ឋាភិបាលទេខ្ញុំមកមុន ។

ដារ៉ា : តើពេលណាពូចូលស្រុកចូលភូមិវិញ?

ជឿន : ចូលគ្រាន់តែដឹងថាគេរត់ទៅនោះអស់ហើយខ្ញុំរត់ចូលមកស្រុកភូមិវិញ មកធ្វើឆ្មោតគេចាត់ឲ្យខ្ញុំ ធ្វើឆ្មោតគេជម្លៀសប្រជាជនទៅនៅក្បែរឈូកនោះ ខ្ញុំនៅឡើងឆ្មោតម៉ាគ្រូមផ្ទះនៅនោះ ។

ដារ៉ា : រដ្ឋអំណាចគេអត់មានរករឿងអីទេ?

ជឿន : ករឿងណាកើតបើខ្ញុំចុះមកគេចាត់ឲ្យធ្វើ ហើយដល់ហើយគេត្រូវការរើសខ្ញុំទៅធ្វើក-៥នោះ ខ្ញុំដើម្បីលប់លៀងកំហុសខ្ញុំកុំឲ្យមានស្លាកស្នាម ខ្ញុំសុំគេទៅមុនគេសុំទៅក-៥ណឹង ចាញ់គោះ សក់ អស់លីងសួរអ្នកផ្ទះខ្ញុំមើលអត់មានសក់ម៉ាសរសៃនៅលើក្បាលទេ ។

ដារ៉ា : កាលណឹងពូដូចជាធ្លាប់តស៊ូអីដែលនៅសម័យប៉ុល ពតលំបាកវេទនាអីដែលហេតុអីក៏ពូចាញ់?

ជឿន : ការធ្វើសង្គ្រាម វាលំបាកណាស់អាអូន ។

ដារ៉ា : ចង់និយាយថាពូទទួលការលំបាកចឹង ហើយពេលដែលពូទៅក-៥ចាញ់ចឹងអី ដូចជាវាមិន ទំនង?

ជឿន : ទេ! មកវិញណឹងអត់មានកំហឹងអីទេ ខាងរាជរដ្ឋាភិបាលយើងសព្វថ្ងៃណឹង គេបំពាក់មេដៃ ឥស្សរយសឲ្យខ្ញុំចឹង ទៅអាស្ពាន់សនេះណា ខ្ញុំទុករហូតដល់ថ្ងៃនេះដែរ មេដៃឥស្សរយសដើរ

ទៅទីណា កាលនៅមានសុពលភាពដើរទៅទីណាក៏គេអត់ហាមអត់ឃាត់ យើងធ្វើស្អីក៏គេអត់មាន..គេបើកសិទ្ធិទូលាយយើងណាស ។

ដារ៉ា ៖ ពូបាន ដូចជាពូបានបូជាកម្លាំងកាយ ចិត្តដើម្បីការពារមាតុភូមិចឹងហេ? ហើយទទួលបានមេដៃណឹងហេ?

ជឿន ៖ មេដៃឥស្សរយសគេ រាជរដ្ឋាភិបាលយើងណឹង ទោក៥ណឹងសម័យណឹង សង្គមណឹង ។

ដារ៉ា ៖ បើនិយាយទោក៥ពេលទៅដល់ការងារធ្វើអីខ្លះពូខ្ញុំធ្លាប់ឮតែចឹង?

ជឿន ៖ ក៥ណឹងទៅឆ្កាព្រៃ ធ្វើថ្នល់ ជញ្ជូនគ្រាប់ សែនរបួសសែនខ្មោច ។

ដារ៉ា ៖ បើចាញ់ចាញ់របៀបមេចទៅ?

ជឿន ៖ ចាញ់គ្រូនចាញ់ ។

ដារ៉ា ៖ ចាញ់ទឹកចាញ់ដី?

ជឿន ៖ បាទ ចាញ់ទឹកចាញ់ដី កាលណឹងមានអីងាប់ចង់តែអស់នៅសល់តែតិច ខ្ញុំមានសក់ណាបើប្រៀបធៀបទៅនៅលើក្បាលខ្ញុំមានប្រហែល២០សរសៃគោះអស់ ហើយចាក់ពេទ្យរដ្ឋមើលមើខូចភ្នៅអស់ហើយខូងភ្នៅសាច់ដុំ ដល់ពេលខ្ញុំគ្រូនខ្លាំងពេកខ្ញុំទិញថ្នាំយកមកចាក់ខ្លួនឯងខូងភ្នៅអស់អត់ជា ។

ដារ៉ា ៖ ដល់ពេលជាជានឹងអី?

ជឿន ៖ ខ្ញុំជានឹងឫសកន្ទ្រាំងខែតនិងឫសក្អឹង ខ្ញុំដេកថ្ងៃទៅដូចសម័យខ្មោចអីខ្ញុំគាត់ប្រាប់ថាអែងដល់ទៅអញ្ជើញគ្រូព្រះរាមអង្គរហើយឥសីប្រោសសត្វមកដាំដឹកទៅបានជាហើយ ។

ដារ៉ា ៖ មេចបានចឹង?

ជឿន ៖ ដូចជាយល់សប់ថ្ងៃណឹងណាទៅអញ្ជើញគ្រូថ្ងៃត្រង់ កាលណឹងដើមត្នោតវានៅមានដបូកផ្ទះខ្ញុំខាងកើតណឹង ដូចជាមិនអស់ចិត្ត ថ្ងៃត្រង់ងើបពីដេកឡើងយកកាំបិតមួយចបមួយ មកជីកឫសកន្ទ្រានខែត្រ ហើយឫសក្អឹងនៅពីក្រោមឫសកន្ទ្រានខែត្រ ខ្ញុំកាត់យកឫសកន្ទ្រានខែត្រ៧កំណាត់ ឫសក្អឹង៧កំណាត់យកដាំទឹកដឹក ជារហូតដល់ថ្ងៃណឹង អត់ដែលគ្រូនចាញ់ជារហូតដាច់មិតតែម៉ង ។

ដារ៉ា ៖ ពូពិសាប៉ុន្មានឆ្នាំង?

ជឿន ៖ តែមួយឆ្នាំង ។

ដារ៉ា ៖ ជាម៉ងពូអត់មានទៅកាត់យកមកស្ងោរទៀតទេ?

ដឿន : បាទ តែមួយឆ្នាំង តែម៉ាដងណឹង តែបុសក្ទឹង/កំណាត់បុសកន្ទ្រាំងខែត/កំណាត់តែម៉ាឆ្នាំង ណឹងរហូត សួរអ្នកផ្ទះខ្ញុំអត់ដែលឈឺអត់ដែលគ្រុនរហូត ។

ដារ៉ា : ដូចថាពេលមានចិនហើយអ្នកផ្សេងៗឈឺគ្រុនចាញ់ខ្លាំងចិន?

ដឿន : ខ្ញុំប្រាប់ទៅគេអត់ជាផងគេយកទៅផឹកទៅអត់ជាផង ជាតែខ្ញុំមួយ ។

ដារ៉ា : វាអាចជាជំនឿអីដែលពូណេះ?

ដឿន : បាទ ដូចថាទាល់តំរិះដើរចាក់ថ្នាំ គ្រាប់គ្រូចឆ្មាបុក/គ្រាប់អាទទឹងថ្ងៃអីណាឲ្យតែពូគេប្រាប់ឲ្យ អ្នកផ្ទះខ្ញុំរកផឹកអស់ហើយអត់ជាទេ ។ ដល់ជាដូចខ្ញុំថាចិនណាក្នុងនាមយល់សប់ដូចខ្មោចអ៊ីខ្ញុំមក ប្រាប់ចិន ហើយជារហូតដល់ថ្ងៃណឹងមិនតិចឆ្នាំទេណា២០ ៣០ឆ្នាំមក ។

ដារ៉ា : ក្នុងចិត្តពូថាមកដល់សព្វថ្ងៃ បានរស់រានសុខសប្បាយនៅក្នុងភូមិចិន ហើយដល់ពេលនឹកគិត ត្រឡប់ទៅក្រោយវិញ ពូមានការសោកស្ដាយក្នុងការចូលរួមពេលទ័ពខ្មែរក្រហម?

ដឿន : ការសោកស្ដាយចេះទេ បានជាពូអត់មានការសោកស្ដាយ នឹកឃើញថាជីវិតមនុស្សគ្រប់រូប មិនមែនអ្នកណាមួយរស់ដោយឯកឯង ឬមួយអ្នកណាមួយកើតមកហើយ អត់មានទុក្ខវេទនា អត់មានជួបការលំបាកគ្រប់បែបយ៉ាង តែងតែមានទោះបីចង់មិនចង់ ទោះបីក្រខ្សត់អត់ឃ្លាន អី គឺត្រូវអ្នកនោះ ឯងជួបនូវគ្រោះវិប្បត្តិគ្រប់ៗរូបចិន គ្រាន់តែខ្លះគេជួបខាងម្ខប់ខ្លះ គេជួប វេទនាហាលភ្លៀងខាងខ្យល់ចិនទៅណា ។ ដូច្នេះនឹកឃើញជានិស្ស័យផលកម្មរបស់មនុស្សចិន ទៅអទ់មានតូច ចិត្តនឹងវាសនាហើយអត់ថា អញ់ហ៉េត្រូវតែធ្វើចេះមួយចេះពីអត់ទេ នឹក ឃើញព្រហ្មលិខិត គេកំណត់មោចិនហើយទ្រាំទៅតាមដំណើរ ។

ដារ៉ា : ចុះបញ្ហាក-៥?

ដឿន : កាលក-៥ក៏ចិន បើសិនជាខ្ញុំមិនទៅច្បាស់ជាជួររាជរដ្ឋាភិបាល គេថាយើងណឹងមានបង្អែក មួយដ៏ធំ បានអត់ហ៊ានលះបង់ខ្លួនដើម្បីបំរើដល់ជាតិ ។

ដារ៉ា : ចុះពូមានតូចចិត្តតូចថ្លើមអីទេពេលរើសក៥?

ដឿន : តូចចិត្តតូចថ្លើមប៉ុននេះដែល គេបំពាក់មេដៃឥស្សរយសដល់យើងប្រៀប គេប្រគល់សិទ្ធិមួយ ដ៏ធំខ្ញុំដល់ពេលអស់រយៈពេលដែលគេប្រើក-៥ ដូចអាមេដៃឥស្សរយសណឹង វាអស់សុពល ភាព ទៅគេលែងរវិលជាមួយយើងទៅគ្រាន់តែតូចចិត្តប៉ុណ្ណឹង ។

ដារ៉ា : ពូនៅសល់មេដៃណឹងដែល?

ដឿន : នៅតើ ។

ដារ៉ា : ចិនខ្ញុំសុំមើលផង ។

ដឿន ៖ អ្នកផ្ទះគេទុកណា ម៉ែវាទុកនៅណាមេដៃឥស្សរ កាលមុនទុកដែល អត់មានទេចោលបាត់អស់ហើយ (ប្រពន្ធនិយាយ) ។

ដារ៉ា ៖ សុំទោសពូ ពូពិការភ្នែកដោយ...?

ដឿន ៖ ពិការភ្នែកណើងដោយសារសង្គ្រាម សង្គ្រាមជាមួយវៀតណាមណើងមកកាលពីយើងនៅក្មេងវាអត់ឈឺដល់ពេលយើងចាស់ទៅដូចថាវាអាលុងអីៗទៅវាឈឺ នេះអំបែង នេះក៏អំបែងសិតតែអំបែងទាំងអស់កាលធ្វើសង្គ្រាមដូចខ្ញុំបានជំរាបអូនឯងចឹងការចំណាយសាច់ចំណាយឈាមដើម្បីឲ្យចំពោះជាតិមាតុភូមិនិងព្រះពុទ្ធសាសនាអាយុជីវិតខ្ញុំស្លាប់ៗទៅអត់កើតទុក្ខអីទេឲ្យតែបានចូលរួមចំនែកដឹងទេ ។

ដារ៉ា ៖ ភ្នែករបស់ពូពិការពេលដែលពូនិយាយថាបាញ់ត្រូវ?

ដឿន ៖ មិនមែនទេពិការពេលណើងទេ ដល់ពេលត្រូវកន្លែងនេះផ្ទុះមីនគ្នា៧នាក់ស្លាប់អស់នៅតែខ្ញុំមួយទេមីន៦៩មួយ បានខ្ញុំពិការ ត្រូវកន្លែងនេះត្រូវចឹងមកដៃនេះបានខ្ញុំពិការ ។

ដារ៉ា ៖ ក្រោយ៧៩ទេអីពូ?

ដឿន ៖ បាទ វើជាមួយយួន វាអត់អីទេចាត់ទុកជាធម្មតាទៅចុះម៉ាជីវិតរបស់ខ្ញុំសំរាប់ជាតិចំណាយជូនជាតិប៉ុណ្ណឹងសាច់ខ្ញុំ ភ្នែកខ្ញុំ ឆ្អឹងខ្ញុំអានេះឆ្អឹងឆែបម៉ាជំហ៊ាងសាច់ខ្ញុំ ចំណាយទាំងប៉ុន្មានគឺថាចំណាយជូនជាតិមាតុភូមិព្រះពុទ្ធសាសនាទៅចុះ សំរាប់ជីវិតខ្ញុំទៅអនាគតជាតិឬក៏ជាតិហ្នឹងខ្ញុំមិនហ៊ាន ថា ថាចឹងទៅចុះនិយាយចេះការលះបោះដើម្បីជាតិមាតុភូមិនិងព្រះពុទ្ធសាសនា អត់តូចចិត្តទេអាត្រង់ថាចំណាយកម្លាំងខ្ញុំទៅក៏ ខ្ញុំចាត់ទុកជាកម្មផលរបស់ខ្ញុំ ចឹងទេអូ? ខ្ញុំអត់មានគិតពីរឿងអីគិតពីរឿងប្រកបអាជីវកម្មចិញ្ចឹមជីវិតប្រពន្ធកូនខ្ញុំឲ្យបានត្រឹមម៉ាឆ្អែតបានហើយ មិនបាច់ចង់មានពេកទេ មានក៏មិនមានដែលចំណាស់នេះហើយរកលែងបានហើយដឹងទេ ។

ដារ៉ា ៖ ពូមានបានតាមដាន រឿងតុលាការកាត់ទោសខ្មែរក្រហមទេ?

ដឿន ៖ អត់ទេ អត់យកចិត្តទុកដាក់ទេនឹកឃើញចេះអាអូន កាត់ទោសក៏មែនពិតអំពើយុត្តិធម៌ អយុត្តិធម៌គង់តែគេរកឃើញឲ្យទេ មិនថាសម័យនេះឬសម័យពីមុនមោទេ អំពើយុត្តិធម៌ពិតជារកឃើញនៅពេលខាងមុខ ប៉ុន្តែមិនដឹងនៅពេលណាមិនថាសង្គមនេះល្អ សង្គមនេះអាក្រក់ឬសង្គមនេះពុករលួយឬសង្គមនេះត្រឹមត្រូវអីខ្ញុំអត់ថា ខ្ញុំថាកសាងឲ្យល្អក្នុងភាពជាយុត្តិធម៌ចំពោះរូបខ្ញុំដើម្បីជាតិ ព្រះពុទ្ធសាសនានិងទឹកដី ឲ្យតែបានទឹកដី ជាតិ សាសនាខ្ញុំស្ម័គ្រចិត្តទាំងអស់បើក្រៅពីជាតិ ទឹកដី ព្រះពុទ្ធសាសនា អ្នកឯងព្រើអំពើអយុត្តិធម៌ខ្ញុំក៏អត់ពេញចិត្ត អ្នក

ឯងប្រើអ្វីខុសពីឆន្ទៈ មនសិការរបស់ខ្ញុំក៏អត់ពេញចិត្តទាំងអស់ ក៏ប៉ុន្តែអត់ថាទេគ្រាន់តែចាំទុកមួយអំលើទៅចុះធម្មតាៗ ជានិស្ស័យព្រហ្មលិខិតខ្ញុំចារមកហើយណាលោកក្មួយ និយាយទៅប្រឡោះនេះទៅចុះកុំឲ្យមានការសង្ស័យច្រើនៗ

ដារ៉ា ៖ ចឹងពួកខ្ញុំអត់មានអីសួរអ៊ំច្រើនទៀតទេ ប្រសិនអ៊ំយល់ថា កន្លែងណាមានការខ្វះខាតអីចង់បន្ថែមអី សូមអ៊ំសួរមកចុះៗ

ជឿន ៖ ការបន្ថែមបន្ថយនេះអត់មានការបន្ថែមបន្ថយអីទេ គ្រាន់តែការសុំណើរសួរលោកក្មួយទាំងពីរនាក់នេះខ្ញុំសូមត្រេកអរ ព្រោះតាំងពីក្មេងមកដល់ចំណាស់នេះ អត់មានខាងអ្នកកាសែត ខាងគ្រូមអង្គការណាផ្សេងៗ មកសំណេះសំណាលទំនាក់ទំនងសាកសួរ ឬក៏សំភាសដូចអាប្អូនឯងនេះទេណាអត់មានទេៗ ដូច្នេះថ្ងៃនេះជាភ័ព្វវាសនាមួយរបស់ពូដ៏ខ្ពស់ខ្ពស់បំផុត សំរាប់ពូដែលមានវាសនាជាមួយអាអូនឯង មកសាកសួរពីរឿងនេះរឿងនោះ ដើម្បីឲ្យពូទំនាក់ទំនងក្នុងភាពជាឧត្តុង្គឧត្តមចំពោះរូបប្អូន ណេះចឹងហេស? ដូច្នេះពូសុំត្រេកអរៗ

ដារ៉ា ៖ ចឹងមានន័យថា ពេលពូបាននិយាយរឿងរ៉ាវចឹង មកប្រាប់ពួកខ្ញុំពូបានធូរស្បើយក្នុងចិត្តចឹងដែល?

ជឿន ៖ និយាយរឿងអស់ទាំងនេះវាមិនធូរស្បើយអីទេ ប៉ុន្តែវារីករាយចំពោះអាអូនឯងមានប្រជាប្រិយភាពមកសួរពូចឹងណាវាអរចឹងទៅវិញទេៗ បើរឿងរ៉ាវវានិយាយប្រាប់អាអូនឯងវាអត់ធូរទេៗ

ដារ៉ា ៖ ចង់និយាយថាពេលពួកខ្ញុំបានមកសួរនាំពូទៅអារម្មណ៍..?

ជឿន ៖ រីករាយខាងផ្លូវចិត្តទៅវិញទេមិនមែនថាសប្បាយពីរឿងនិយាយពីរឿងប្រវត្តិដែលឆ្លងកាត់មកហើយសំរាប់ជូនអាអូនឯងហើយធូស្រាលអត់ទេៗ

ដារ៉ា ៖ ខ្ញុំយល់ៗ

ជឿន ៖ ស្តាប់ឲ្យទាន់ណាកុំថាបាននិយាយពីរឿងអស់នេះខ្ញុំធូរចិត្តអីអត់ទេ ធូរចិត្តរឿងអាអូនឯងទាំងពរូបនឹងមានការទំនាក់ទំនងសំណេះសំណាលជាមួយពូសូមត្រេកអរតែប៉ុណ្ណឹងទេសប្បាយចិត្តអាត្រង់ណឹងវិញទេបើឲ្យថារឿងអីផ្សេងៗដែលបានអធិប្បាយរ៉ៃរាប់បានជូនអាអូនឯងអត់ធូរទេអាអូនរឿងអស់ទាំងណឹងៗ

ដារ៉ា ៖ ចឹងពួកខ្ញុំអគ្រុណពូច្រើនណាៗ

ជឿន ៖ សាធុកៗៗណា សុខសប្បាយ អូចតមួយទៀតចេះតែចតទៅអាអូនៗ

«ចប់»